**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៩៤ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ឧត្ដមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៦៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្ដមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានឧត្ដមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់។

## ជំពូកទី២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន

**មាត្រា២ .-**

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានតួនាទីសម្របសម្រួលការងាររបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ និងមានភារកិច្ចដូចតទៅ៖

- រៀបចំកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ជាប្រចាំខែ និងរៀងរាល់៦ខែម្តង ព្រមទាំងកិច្ចប្រជុំផ្សេងៗទៀត
- ទទួលនិងរក្សាឯកសាររបស់ប្រតិភូគណបក្សដែលមានជាសំណើឬរបាយការណ៍នានា ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច
- លើកយោបល់លើសំណើឬរបាយការណ៍របស់ប្រតិភូគណបក្ស ដើម្បីដាក់ជូននាយករដ្ឋមន្ត្រី
- សម្របសម្រួលការបំពេញបេសកកម្មនិងការងារប្រចាំថ្ងៃរបស់ប្រតិភូគណបក្ស
- សម្របសម្រួលសម្ភារៈនិងថវិការបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ក្នុងការបំពេញការងារ
- ធ្វើផែនការថវិកាប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេច
- គ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក ឯកសារស្ថិតិ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា និងកិច្ចការផ្សេងៗទៀត
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូននាយករដ្ឋមន្ត្រី តាមរយៈរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយករដ្ឋមន្ត្រី។

**មាត្រា៣ .-**

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដឹកនាំដោយប្រធានមួយរូប និងមានមន្ត្រីនិងបុគ្គលិកមួយចំនួនក្រោមឱវាទ។

**មាត្រា៤ .-**

គណបក្សនយោបាយនីមួយៗដែលចូលរួមក្នុងឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ត្រូវចាត់តាំងមន្ត្រីរបស់ខ្លួនចំនួនមួយរូប មកបម្រើការក្នុងលេខាធិការដ្ឋានស្របតាមមាត្រា១៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៦៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

មន្ត្រីគណបក្សនយោបាយដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ បំពេញការងារជាមន្ត្រីទំនាក់ទំនង និងសម្របសម្រួលការងាររបស់ប្រតិភូគណបក្សសាមី ក្នុងក្របខ័ណ្ឌឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ តាមរយៈលេខាធិការដ្ឋាន។

**មាត្រា៥ .-**

ប្រធានលេខាធិការដ្ឋានអាចស្នើសុំមន្ត្រីជំនាញនិងបុគ្គលិកបច្ចេកទេសមួយចំនួនតាមការចាំបាច់ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីជាធរមាន។ មន្ត្រីជំនាញនិងបុគ្គលិកបច្ចេកទេសត្រូវជ្រើសរើសចេញពីមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈនិង/ឬក្រៅក្របខ័ណ្ឌមុខងារសាធារណៈ។

**មាត្រា៦ .-**

មន្ត្រីគ្រប់ប្រភេទនិងគ្រប់ថ្នាក់ដូចមានចែងក្នុងមាត្រា៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ត្រូវបញ្ចប់ការងាររបស់ខ្លួនក្នុងលេខាធិការដ្ឋាននៅពេលអាណត្តិរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវបានបញ្ចប់។

**មាត្រា៧ .-**

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានរចនាសម្ព័ន្ធដូចតទៅ៖

- ការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
- ការិយាល័យសរុប បណ្ណសារ និងព័ត៌មានវិទ្យា
- ការិយាល័យសាធារណមតិនិងជំនួយការប្រជាជន
- ការិយាល័យនីតិកម្ម
- ការិយាល័យព័ត៌មាននិងទំនាក់ទំនងសាធារណៈ។

## ជំពូកទី៣

## ប្រភពធនធាន

**មាត្រា៨ .-**

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននូវមូលនិធិដែលមានមកពីដៃគូអភិវឌ្ឍនិងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងារ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

អនុក្រឹត្យលេខ១២២ អនក្រ.បក. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ